កម្មវិធីស្រាវជ្រាវ និងស្វែងយល់អំពីច្បាប់

www.lorkremlaw.wordpress.com

Tel: 069 25 55 25

# ក្រមងកំណាព្យ

# ស្តីពី

# ច្បាប់ប្រុស - ច្បាប់ស្រី



និពន្ធឡើងដោយបណ្ឌិត ម៉ឺន ម៉ៃ

# ច្បាប់ប្រុស

នេះបទព្រហ្មគីតិ
ពីព្រេងព្រឹទ្ធទុកទូន្មាន
ចែងចងជានិទាន
ទុកគ្រាន់មើលជាច្បាប់ថ្មី។
ឲ្យអស់កូនចៅក្រោយ
ស្តាប់កុំឲ្យភ្លេចស្មារតី
ប្រដៅទាំងប្រុសស្រី
យកទុកខ្លួនគ្រប់អាត្មា។
ធម្មតាកើតជាមនុស្ស
ទោះស្រីប្រុសក្រណាស់ណា
ក្រគិតក្នុងចិន្តា
ឲ្យបានដឹងសមនិងគួរ។
នឹងអស់ញាតិសន្តាន
សោះគេមានពាក្យថាជួ
កុំឆ្មើងកុំតែងតួ
ធ្វើកំប៉ោងកុំពាក្យធំ។
នឹងដើរដូចភុជង្គ
ឲ្យខិនអង្គអាចបារម្ភ
ឲ្យត្រូវនឹងច្បាប់ក្រម
គួរប្រតិបត្តិកុំឲ្យឆ្គង។
រៀនបទរៀនបាទចាស់
កុំប្រឡាសលើរៀមច្បង
ស្រដីនឹងអ្នកផង
ពាក្យឲ្យគួរកុំឯងវឺ។
អឺអើអញដាច់សាច់
ឆ្គងពាក្យពេចន៍គេស្រដី
ដើមដៀលឲ្យអប្រិយ
ស្រដីថាកូនអត់ពូជ។
ចាស់ទុំមិនប្រដៅ
ជេរកូនចៅទើបវាខូច
គេថាកូនឥតពូជ
មិនដឹងច្បាប់នឹងចាស់ទុំ។
គេដៀលដល់ម៉ែឪ
កេរ្តិ៍អាស្រូវស្អុយរហ៊ុំ
គេស្តីដើមជៀវជុំ
ជំនៀលនោះដល់មកចាស់។
កុំកាចកុំស្លូតពេក
កុំចំអៀករៀនរហ័ស
កុំខ្លាចកុំប៊ានណាស់
ឲ្យរំពឹងរំពៃគ្រប់។
ទោះដេកឲ្យរហ័ស
ភ្ញាក់មុនចាស់ដោះឡើងលុប
មុខមាត់មើលឲ្យគ្រប់
ទ្រព្យរបស់សឹមដេកវិញ។

ស្លាម្លូស៊ីឲ្យច្រៀក
កុំបីបៀកទាំងមូលមិញ
តូចធំឲ្យច្រៀកចេញ
តាមពាក្យចាស់ថាអភ័ព្វ។
ដេកយូរកុំដេកយូរ
ហើយទទូរដូចគេងាប់
សំពត់ស្លៀកឲ្យខ្ជាប់
កុំឲ្យអាក្រាតក្រៅខ្លួន។
នឹងដេកកុំទ្រមក់
ឲ្យលង់លក់ក្រៅពីក្បួន
បើភ្ញាក់ឲ្យដឹងខ្លួន
ឡើងអង្គុយកុំមាត់ខ្លាំង។
ប្រែប្រាណប្រុងវិញ្ញាណ
ខ្លាចក្រែងមានចោរចិត្តខ្លាំង
ប្រួញប្រាណប្របជញ្ជាំង
ជញ្ជូនទ្រព្យលួចយកចេញ។
បើឥតមោះមន្ទិល
កុំឲ្យខ្ជិលដេកទៅវិញ
ភ្ញាក់ហើយឲ្យក្រោកចេញ
រកជក់ថ្នាំស៊ីម្លូស្លា។
ទោះពេលពន់ព្រលប់
គន់ឲ្យគ្រប់ទ្រព្យនានា
កាំបិតខាងអាត្មា
ឲ្យសិតទឹកដាក់ចុងជើង។
ប្រអប់ដាក់ទឹមស្នា
ថ្វាយទេព្តារក្សាយើង
ហើយឲ្យបំពក់ភ្លើង
នៅក្រានក្រៅកុំឲ្យដាច់។
កុំឲ្យអស់រលើង
រលត់ធេងហើយថាភ្លេច
សព្វថ្ងៃមើលកុំដាច់
កុំដើរយកពីផ្ទះគេ។
ថែទាំមើលជើងក្រាន
ឲ្យឧសមានកុំទំនេរ
បង្កាត់បង្កើតកេរ្តិ៍
កុំប្រហែសឲ្យស្ងួនស្យុង។
ប្រយ័ត្នក្រែងក្រងាយ
ពុំសប្បាយឈឺពោះពុង
បង្កាត់កម្តៅអង្គ
អុជបំភ្លឺមើលនេះនោះ។
មានកាលយប់ងងឹត
ភ្លេចមិនគិតជួនកូនចុះ
គ្មានភ្លើងអុជចន្លុះ
ក្រានរលុះរលត់ធេង។
រត់រកភ្លើងសស្រាក់
ព្រួយលំបាកតែខ្លួនឯង
ហេតុខ្ជិលពុំគិតក្រែង
ក្រយប់ថ្ងៃព្រួយដើរឆ្ងាយ។

ហើយឲ្យថែទាំទឹក ទោះយប់ព្រឹកកុំគិតងាយ
ឯងដាក់ក្អមរាត់រាយ សព្វពួច ពាងអាងអុងធំ។
កុំឲ្យស្ងួតក្អមធេង អស់រលើងពីពាងធំ
គ្មានសោះនោះមិនសម ជួនក្រែងក្រងាយយប់ថ្ងៃ។
ទោះដើរទៅឆ្ងាយជិត កាន់កាំបិតកំឯរវែង
ក្រែងមានមែកឈើព្រៃ កាប់កាន់មកធ្វើអុស។
ជួនកាលក្រែងមានបន្លា មុតអាត្មាគ្រាន់ចាក់ជួស
ជាគ្រឿងគ្រប់មិនខុស ការសត្រូវទោះឆ្មាឆ្កែ។
ដើរព្រៃឲ្យមើលលើ ឃើញស្លឹកឈើជាបន្លែ
កាប់កាន់កុំដៃទេ អង្គុយគន់មើលឆ្វេងស្តាំ។
ក្រែងមានឈើព្រៃងាប់ គួរកាច់កាប់យកជាថ្នាំ
ធ្វើក្រានគ្រាន់ដណ្តាំ បាយបានឆ្អិនឆាប់ដូចចិត្ត។
សោះស្រីស្រដីបាន បើអុសមានមិនព្រួយគិត
សព្វថ្ងៃប្រុងគំនិត ថែទាំទើបគង់របស់។
មាសប្រាក់ស្រូវអង្ករ ទុកឲ្យល្អកុំសប្បុរស
សំចៃកុំឲ្យអស់ មើលថែថួនខ្លួនឯងណា។
សូវស្តួចកុំឲ្យដាច់ បើវាតិចឲ្យឧស្សាហ៍
រិះរកផ្សំទៀតណា ឲ្យបានច្រើនក្រវើន ទុក។
នឹងចាយឲ្យគិតក្រោយ ទោះនឹងឲ្យមើលមុខៗ
កុំឲ្យស៊ុកគ្រលុក ទោះនឹងទុកឲ្យចំណាំ។
រដូវធ្វើចម្ការ ឲ្យឧស្សាហ៍គ្រឿងគ្រាប់ដាំ
ស្លឹកគ្រៃខ្ទីត្រប់ត្រុំ ត្រាវត្រសក់សព្វបន្លែ។
កុំខ្ជិលកុំច្រអូស ទៅងង្ហូសរត់សុំគេ
គេមិនឲ្យឯងទេ តែគឺមោះព្រោះខ្ជិលដាំ។

ទោះធ្វើស្រែចម្ការ ឲ្យឧស្សាហ៍មើលថែទាំ
កុំខ្ជិលកុំប្រចាំ ចបចូកជីកស្មៅវល្លិផង។
កុំឲ្យបង់កម្លាំង ទោះខែប្រាំងប្រើឲ្យដង
ទឹកទៅស្រោចស្រង់ផង ឲ្យលូតលាស់មានផ្កាផ្លែ។
ធ្វើការកុំគិតព្រួយ ខ្លួនឯងមួយកុំត្អូញត្អែរ
ខ្លាំងខ្សោយកុំឲ្យល្ហែ ខ្លាចតែនឿយហើយមិនធ្វើ។
ជាងយប់បិតឫស្សី ត្បាញជាល្អីតៅកញ្ជើ
កុំឲ្យស្រីស្តីលើ ឥតអំពើធ្វើលេងទៅ។
កុំទុកដៃទទេ ជាងទំនេរបោចស្មៅព្រៅ
ខាងផ្ទះខាងលំនៅ ឲ្យវាលកាលកើតសុខា។
ឲ្យមានក្តីបារម្ភ ធ្វើស្រែកុំចោលចម្ការ
នឹងដែកកាំបិតព្រា ទុកឲ្យជាកុំឲ្យបាត់។
ដេកយប់ឲ្យរាំងទ្វារ ទ្រព្យជាៗប្រុងប្រយ័ត្ន
ត្រចៀកចាំកុំភ្លាត់ កុំភ្លេចចោលមិនដឹងខ្លួន។
ប្រយ័ត្នប្រយោជន៍យូរ ទោះលក់ដូរមើលថែធួន
ទោះទ្រព្យរបស់ខ្លួន ឲ្យសួរកូនសួរប្រពន្ធ។
កុំអាងឯងជាប្រុស ចាយរបស់មិនគិតគន់
មិនដឹងដល់ប្រពន្ធ ព្រមព្រៀងគ្នាឥតបើថា។
ទោះបីបើបងប្អូន ពឹងរកខ្លួនទៅណាៗ
ទោះទៅលេងឥតការ ឥតគេរកដើរឆ្ងាយជិត។
ឲ្យប្រាប់អ្នកនៅផ្ទះ កុំរលះឥតគំនិត
គេភ័យព្រួយចិត្តគិត ព្រោះមិនដឹងជាទៅណា។
បើទៅជាមានភ័ព្វ ប្រសើរគាប់នោះឥតថា
ប្រសិនពានពស់ខ្លា ខ្យល់ចាប់ចុកឥតគេសម។

ទោះដើរមានដំណឹង ឲ្យរំពឹងគិតបារម្ភ
នឹងដើរឮឲ្យសម យប់ព្រលប់ឲ្យមាត់ក។
កុំស្ទៀមកុំស្ទាត់ពួន លបលាក់ខ្លួនខ្លាចមិនល្អ
ឲ្យមើលឲ្យមាត់ក ដើរឲ្យស្មោះសោះគេថា។
ទោះខ្លួនជាប៉ុន្មាន ពាក្យសន្ដានវែងមុសា
គេម៉ែ មកអាត្មា តាមដំណឹងដំណើរខុស។
កូនអើយបាកុំធ្លោយ កុំធ្លាយឲ្យអាប់កេរ្តិ៍យស
ធម្មតាកើតជាប្រុស ឲ្យរករៀនច្បាប់មាត្រា។
លោកថាហៅឆ្កួតបី មួយឆ្កួតស្រីមួយឆ្កួតស្រា
មួយឆ្កួតល្បែងពាលា លេងបៀរប៉ោធ្វ កំតាត់។
ទាក់មាន់ទាក់ទទា ជល់ភ្នាល់គ្នាបរបាញ់សត្វ
អន្ទាក់ដាក់បង្កាត់ ល្បែងអស់នោះមិនកំណើត។
ធម្មតាប៉ោនិងបៀ មិនដែលខ្មែរណានឹងកើត
មិនឮមានកំណើត មានតែលិចលង់ខ្លួនទេ។
ជួនកាលគេចាញ់ឯង រៀងរាល់ល្បែងគេនឹងរេ
មានកាលឯងចាញ់គេ កុំទុកចិត្តថាឯងប៉ិន។
ពីព្រឹកស្លៀកហូលជរ ល្ងាចស្លៀកសខ្វះចងក្បិន
ពីព្រឹកត្បូកក្បាលចិន ល្ងាចមិនទាន់ចិនដាក់ខ្នោះ។
ជួនកាលវាចងជើង ព្យួរខ្ពស់ឡើងដាំក្បាលចុះ
ភ្នែកស្លឹងតឹងក្រញុះ វាទារប្រាក់ឲ្យបានឆាប់។
មើលមុខល្អមិនតិចអី មិនខ្វាសស្រីផ្សារឈរស្តាប់
មុខមិញដូចគេស្លាប់ មាត់ស្មេញស្មាញពេបកូនក្មេង។
ស្រែកថ្ងូរអេះអូយអឺយ អាចិកអើយអាណិតលែង
អញរកប្រាក់ឲ្យឯង ឲ្យអាចិកស្អែកនេះបាន។

ចិនឮព្រមស្រាយមក　បណ្ដើររកប្រាក់សន្ទាន
តឹងទារទាល់តែបាន　ទ្រព្យឲ្យទៅទើបវាលែង។
អ្នកអាយអ្នកអើយកុំ　គួរបារម្ភទាល់តែល្បែង
កុំលកកុំលួកលេង　គួរឲ្យវាងឲ្យវៀរសោះ។
កុំឈរកុំឈប់ចិត្ត　ក្រែងមិនអត់បង់កេរ្តិ៍កោះ
កុំល្បងល្បែងនោះសោះ　គួរឲ្យដោះឲ្យដើរចេញ។
ច្បាប់នេះចាំរាល់ខ្លួន　ទោះបងប្អូនមិត្តសម្លាញ់
ពឹងខ្លួនឯងឲ្យចេញ　ធានាទ្រព្យគេយកទៅ។
ឯទ្រព្យបានទៅវា　ឯងធានាស្រាប់តែនៅ
វាបានទ្រព្យយកទៅ　ខ្លួនឯងនៅធានាស្រាប់។
ដល់គេមកតឹងទារ　អ្នកធានាក៏បានឆាប់
មិនបានគេប្រចាប់　ទៅជាខ្ញុំព្រោះធានា។
ទោះបងប្អូនធុរៈ　ក្រជំពាក់គេតឹងទារ
បើមានទ្រព្យជួយជា　កុំធានាណាអ្នកអាយ។
កូនអើយចូរបាចាំ　ឪពុកផ្ដាំកុំបីណាយ
ប្រយ័ត្នរាល់រូបកាយ　កុំឲ្យភ្លេចពាក្យនេះណា។
មួយទៀតហៅភ្លេតស្រី　គួរកុំបីសេពកាមា
វាតែងទាញអាត្មា　នាំវង្វេងភ្លេចបាបបុណ្យ។
ភ្លេចទានសីលសូន្យសោះ　ភ្លេចឃ្លាងខ្លោះដល់ជីពជន្ម
ភ្លេចទោសភ្លេចទាំងគុណ　ភ្លេចទាំងការកាន់វសាយ។
បង្កើតតែទុក្ខទោស　បើបានសុខសឹងប្រែក្លាយ
បង្កើតក្ដៅក្រហាយ　ឲ្យទាស់តែងខឹងនឹងគ្នា។
ចងទោសគុំគង្ហួន　មិនគិតខ្លួនខ្លាចមរណា
មានកាលក្មួយនិងមា　គុំធ្វើគ្នាឲ្យសោះសូន្យ។

បង្កើតតែចិត្តធំ
ចៅគំនុំនឹងជីដូន
ឯបងខឹងនឹងប្អូន
ម្តាយនិងកូនគុំធ្វើគ្នា។
រីខ្ញុំគុំកាប់ម្ចាស់
ឲ្យក្តៅណាស់ក្នុងអង្គា
កើតទោសខឹងនឹងគ្នា
ជាគំនុំពុំត្រាស្បើយ។
មានកាលគេដាក់ឃ្នាង
វាមិនរាងចាលចិត្តឡើយ
លក់ថ្លៃ ខ្ញុំគេហើយ
មិនខ្លាចស្លាប់ដល់អាត្មា។
គេកាប់ដោតទាំងក្បាល
មិនចេះចោលចិត្តឡើយណា
ភ្លេចខ្លួនសូន្យសោះណា
នឹកតែត្រង់សេពសប្បាយ។
រីឯកាមកិលេស
កុំប្រហែសគួរឲ្យណាយ
ស្អិតណាស់ណាអ្នកអាយ
អ្នកអើយកុំគិតសង្ស័យ។
នេះឯងហៅឆ្កួតស្រី
គួរកុំបីឲ្យអាល័យ
ចូរចងចាំសព្វថ្ងៃ
ទុកទូន្មានអង្គអាត្មា។
អ្នកប្រាជ្ញលោកនិទាន
ទុកទូន្មានរាល់រូបា
មួយហៅឆ្កួតសុរា
នោះកុំផឹកវាស្រវឹង។
វានាំភ្លេចវិញ្ញាណ
ភ្លេចសីលទានសោះសូន្យឈឹង
ផឹកហើយមិនដែលនឹង
នាំចិត្តនោះឲ្យធំក្រៃ។
ឯខ្លួនឯងតូចទេ
មើលទៅគេប៉ុនមេដៃ
កម្លាំងឯងស្មើនឹងចៃ
មិនកោតគេតិចឡើយណា។
ក្អេងក្អាងពាក្យកក្អែ
អួតពូកែបទបានស្រា
មិនមានខ្លាចនរណា
ស្រដីកោងរកកលឈ្លោះ។
បញ្ជោរបញ្ជៀសផ្តាស
ជេរវាងវាសមិនចំឈ្មោះ
នាំហេតុតែខាងឈ្លោះ
ឆ្លើយឆ្លងពាក្យឲ្យបានទាក់។
ប្រពន្ធឃើញឃាត់ទៅ
ប្តីមិនត្រូវថាកុំអ្នក
ឯងខឹងលោវាធាក់
ដោយចិត្តធំបទបានស្រា។

មានកាលជួនស្រវឹង ពុំមានដឹងខ្លួនឡើយណា
ដើរវង្វេលដេកផ្កាប់ផ្ងារ ស្រាតសំពត់អស់ពុំដឹង។
គេឃើញអស់ខ្មាសខ្ញុំ ក្មេងជៀវ ជុំសើចទ្រហឹង
ដេកដូចគេស្លាប់ឈឹង ក្អែរក្អួតពាសពេញទាំងខ្លួន។
កំណើតអ្នកផឹកស្រា កុំអួតថាឯងនឹងនួន
ដឹងហើយស្រវឹងបួន ខ្លួនខ្សត់ទេអួតថាមាន។
អ្នកស្លូតទៅជាកាច ឯងអ្នកខ្លាចទៅជាហ៊ាន
ខុសត្រូវទៅបំពាន បំពុលខ្លួនឲ្យបានបាប។
នេះឯងហៅឆ្កួតស្រា ក្នុងធម៌ថាពៀរដំរាប
អ្នកណាផឹកហើយបាប បង់កិត្តិយសពុំសួស្តី។
គួរកុំសេពសុរា នាំអាត្មាឲ្យអប្រិយ
នឹងធ្លាក់ទៅអវចី នរករងទុក្ខវេទនា។
បៃអស់ជនទាំងឡាយ កុំវាយមាយក្នុងអង្គា
ចូរស្តាប់ច្បាប់នេះណា ទុកទូន្មានខ្លួនសព្វថ្ងៃ។
នេះឯងហៅឆ្កួតបី លោកស្រដីក្នុងធម៌ថ្លៃ
បើអ្នកណាមួយនៃ នឹងប្រាថ្នាដោយចំណង។
លោកចងជាឧបមា ឲ្យអ្នកណាមួយផ្ចិតផ្ចង់
យកដែកដុលបោះបង់ ក្នុងភ្លើងប្រាណឆេះច្រាលឆ្អៅ។
បើកាន់ដែកដែលដុត នោះមិនមុតមិនមានក្តៅ
កាន់បាននោះទើបហៅ ចិត្តមុតមែនពិតគិតប្រាណ។
នោះទើបលោកឲ្យធ្វើ នូវអំពើទាំងបីបាន
ដោយធម៌បុរាណ លោកឧបមាដូច្នេះនា។
ចាត់ចែងតែងជាបទ ព្រហ្មប្រាកដកាលបិតា
ប្រដៅខ្ញុំនេះណា សព្វសេចក្តីដូច្នេះនៃ។

កិច្ចកាព្យរាយរៀបរោះ ខ្ញុំនាមឈ្មោះ**បណ្ឌិត ម៉ៃ**

គិតចងជាសេចក្តី ប្រដៅជនចប់ម្លេះហោង៕

# ច្បាប់ស្រី

| | | |
|---|---|---|
| នេះបទកំណត់ចងជា | ភុជង្គលីលា | ចងជាច្បាប់ស្រី។ |
| កាលនាងឥវន្ទវតី | ចរចាកតាមប្តី | គឺបុណ្យកយក្សា។ |
| នាងនឹងត្រាច់ត្រង់តាមប្តី | ចេញចាកអំពី | ពិភពនាគនេះ។ |
| ទៅឋានមនុស្សលោកនាយអេះ | ចូរនាងចាំចេះ | បម្រើស្វាមី។ |
| ធ្វើវត្តប្រតិបត្តិប្រក្រតី | កុំឲ្យស្វាមី | អាក់អន់ចិន្តា។ |
| នាងអើយគម្ពែង[១]ក្រឡា | ជាម្ចាស់សិរសា | កូនកុំមាក់ងាយ។ |
| ហៃកូនស្រីមាសម្តាយ | ក្រណាស់នាងអាយ | តាមដោយច្បាប់ស្រី។ |
| ក្រមួយមិនបានសម្តី | ពាក្យទន់តិចនៃ | ឲ្យញាតិចូលចិត្ត។ |
| ក្រមួយមិនចេះរិះគិត | ឃើញញាតិឆ្ងាយជិត | ហៅឡើងឆីស្លា។ |
| ទោះមានមិនមានក្តីណា | ពាក្យផ្អែមចរចា | ទើបគេស្រឡាញ់។ |
| កុំជួចិត្តស្ទូរកំណាញ់ | មិនមានអស់អញ | នឹងញាតិសន្តាន។ |
| កើតយសរបស់ផងបាន | កើតសុខក្សេមក្សាន្ត | ពីព្រោះកូនស្រី។ |
| ទោះនឹងនិយាយស្រដី | ការកេរជាស្រី | កុំស្តីឡេះឡោះ។ |
| ថាលេងដូចក្មេងញ៉េះញ៉ោះ | ឃើញប្រុសកម្លោះ | សសៀរចូលជិត។ |
| សើចព្រៀងកញ្ជៀងមិនគិត | ប្រុសព្រើលបានចិត្ត | វាប៉ានដោយសារ។ |
| ហៅស្រីអប្រិយឥតការ | ឥតមានឥរិយា | មារយាទក្នុងខ្លួន។ |
| សើរើពុំធ្វើនឹងនួន | ស្រដីមិនមួន | មិនមានអៀនអន់។ |
| ឃើញគេបៀតបែរគយគន់ | សើចស្គួរចំអន់ | ចំអកឲ្យប្រុស។ |
| ហៅស្រីអប្រិយទុយ៌ស | មិនខ្លាចខ្លួនខុស | មារយាទក្រឹត្យក្រម។ |
| ធ្វើការអង្គុយច្រឡំ | នឹងសមពុំសម | ថាឯងជាស្រី។ |
| មិនកោតមិនខ្លាចចិត្តប្តី | ឲ្យប្រុសដទៃ | មាក់ងាយប្តីណា។ |
| ហៅស្រីឥតលក្ខណា | ឥតមានកិរិយា | មារយាទពុំសម។ |

ធ្វើការផងណាប្រើខំ ទោះត្បាញចាក់ដំ នាងខំឲ្យហើយ។
កុំទុកទៅមុខទៀតឡើយ ថាចាំបង្ហើយ កម្រណាស់ណា។
ទោះធ្វើហូលគោមព្រែ[២]ផ្កា ដាក់ត្បាញហើយណា បានស្រេចសឹមធ្វើ។
ធ្វើឲ្យកើតកេរ្តិ៍ប្រសើរ ហើយកុំឲ្យដើរ លេងផ្ទះគេណា។
ឱស្ងួនខ្លឹមខ្លួនរក្សា នាងខំធ្វើការ ទាន់ខ្លួនក្រមុំ។
មានប្ដីបានអ្វីជាខំ រវល់កូនយំ កម្រចេះឆ្លាត។
ព្រួយចិត្តគំនិតចង្អៀត មួយហើយមួយទៀត យំទាវតែឆី។
រីងព្រួយទាំងមួយទាំងពីរ រកបានឲ្យឆី ទើបបានបាត់មាត់។
ទៅកាន់ការធ្វើឲ្យស្ទាត់ ហូលគោមគាត់កាត់ អន្ទងត្បាញទៅ។
កុំទុកក្នុងស្មុគស្មាញនូវ ក្រែងឯល់យូរទៅ ខាតខូចអសារ។
ហៃកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី។
ចូររករៀនយកច្បាប់ស្រី ឲ្យកោតខ្លាចប្ដី គម្ដែងក្រឡា។
ធ្វើវត្តប្រតិបត្តិសោតណា ឲ្យនាងរក្សា ភ្ជក់ភ្លើងទាំងបី។
ឲ្យកាត់ឲ្យគង់ប្រក្រតី សព្វថ្ងៃកុំឲ្យបី ភ្លេចផ្លុំឲ្យឆេះ។
ក្រែងរាលដូចដាលព្រាយប្រេះ កើតក្ដៅរលេះ រលាយអស់អង្គ។
ភ្លើងក្រៅកុំនាំទៅក្នុង ឲ្យឆេះបំផ្លុង ឬផ្លុំបង្កាត់។
ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឲ្យឆេះឯក្រៅ។
អុជអាលបណ្ដាលឲ្យក្ដៅ ដាលឯល់កូនចៅ អសោចអប្រិយ។
ឲ្យនាងខំប្រុងស្មារតី មើលភ្លើងទាំងបី រក្សាឲ្យគង់។
ភ្លើងនោះឲ្យកូនពុំលង់ នឹងឲ្យឧត្តុង ឧត្តមកន្លង។
កើតយសរបស់ទ្រព្យផង បរិបូរឥតហ្មង ប្រសើរក្លាត់ណា។
ភ្លើងមួយនោះឲ្យរក្សា គឺគុណមាតា បិតាស្ងួនគ្រង។
ឲ្យនាងធ្វើដោយគន្លង ប្រណិប័តន៍កុំឆ្គង នឹងម្ដាយឪពុក។
ឲ្យខំថែទាំញ៉ឹកញ៉ុក ចំណីចំណុក ចំណង់អាត្មា។

| | | |
|---|---|---|
| កុំឃ្លានទុកឆីឡើយណា | ឆ្ងាញ់ឈ្ងុយពិសា | ជូនជាប្រក្រតី។ |
| ពាក្យពេចន៍ការកិច្ចអ្វីៗ | អត់ឱនកុំបី | ឲ្យអាក់ចិន្តា។ |
| ភ្លើងមួយគម្តែងក្រឡា | គឺប្តីអាត្មា | បិនថេររួមរ័ក្ស។ |
| ឲ្យនាងប្រណិប័តន៍ជឿជាក់ | កុំធ្វើឲ្យអាក់ | ឲ្យអន់ចិត្តប្តី។ |
| អត់ឱនខ្លាចខ្លួនជាស្រី | កុំឲ្យស្រងី | ទុកគេជាស្នើ។ |
| ទោះកើតហេតុភេទសារពើ | ពាក្យពុំប្រសើរ | ជញ្ជឹងចាំស្តាប់។ |
| ទោះប្តីស្រងីពុំគាប់ | ពុំគួរឲ្យប្រាប់ | បាននឹងឯល់ម្តាយ។ |
| កើតខឹងរែងរីងខ្វះខ្វាយ | ពួពាក្យពីម្តាយ | ខ្សឹបខ្សៀវប្រាប់ប្តី។ |
| មិនក្សាន្តបែកបានពីប្តី | កើតជាសម្តី | សួរចុះសួរឡើង។ |
| ពុំស្ងាត់ស្ងៀមមាត់ចចើង | ជជែកនាំឡើង | ចចើងមិនបាត់។ |
| តតាំងពាក្យខ្លាំងមិនស្ងាត់ | មិនស្ងៀមឲ្យបាត់ | ឲ្យបានទីសុខ។ |
| ជជែកស្នើរបែកទាំងស្រុក | មិនមានហៅសុខ | យូរលង់ឡើយនៃ។ |
| នេះហៅភ្លក់ភ្លើងទាំងបី | ម្តាយផ្តាំកូនស្រី | ឲ្យខំរក្សា។ |
| នាងគម្តែងក្រឡា | ខុសឆ្គងម្តេចម្តា | ម្តាយផ្តាំកូនស្រី។ |
| ឲ្យអត់សង្កត់ហឫទ័យ | កូនកុំស្រងី | ដើមប្តីកំបាំង។ |
| កុំជេរកុំចេញជាខ្លាំង | ខ្សត់ខ្សោយខ្លៅខ្លាំង | នាងកុំមើលងាយ។ |
| ល្មូង់ខ្សោយប្រើឲ្យនិយាយ | ណែនាំលេងលាយ | ឲ្យស្រួលវាចា។ |
| ទោះប្តីស្រងីម្តេចម្តា | ខេខឹងជេរថា | បោះពាក្យទម្ងន់។ |
| ក្រោធក្រេវឆុលឆេវមិនអន់ | មិនអាក់ស្រោកស្រន់ | ដោយចិត្តគ្នាន់ក្នាញ់។ |
| រអ៊ូរទាំទន្ទេញ | ជេរថាជន្លេញ | ត្បិតទាស់នឹងចិត្ត។ |
| ឲ្យកូនស្រីស្ងួនខំអត់ | ឲ្យបានរលត់ | រលាយកំហឹង។ |
| កុំកូនកាន់ខ្លួនប្រែប្រឹង | ឥតបទៅនឹង | អ្នកជាស្វាមី។ |
| ខេខឹងក្រញឹង[៣]សម្តី | មិនគិតខ្លួនស្រី | ស្រងីទ្រគោះ។ |
| ប្រកែកស្តីពាក្យគំរោះ | គំរាមបញ្ឆោះ | បញ្ឆោរឲ្យខឹង។ |

រឹងរូសមើលមុខសម្លឹង សម្លក់ទៅរឹង ចចឹងចង់ឈ្លោះ។
រឹងឆ្លងឆ្លើយពាក្យបញ្ជោះ បំបែកជាឈ្លោះ បំបែរពុំទៀង។
ជេរថាឆ្កែឆ្នាបំព្រៀង ដៀលត្មះបញ្ឆៀង បញ្ឈឺចិត្តប្តី។
បោះបោកប្រទះអ្វីៗ ចាប់ចោលទៅដី បែកបាក់ពុំគិត។
មិនស្រួលទទួលបាត់មាត់ ម្នះម្នាក្នុងចិត្ត ឲ្យបានប្តីចាញ់។
ទើបបានសុខចិត្តជាវិញ ហៅស្រីម្នះម្នេញ អាប់កេរ្តិ៍យសឆ្ងាយ។
ហៅកូនស្រីស្ងួនមាសម្តាយ ខុសណាស់នាងអាយ កុំធ្វើដូចគេ។
ទោះបីបើប្តីនាងជេរ នាងចូលទៅឯ ដំណេកគិតសិន។
ចេញមកនាងយកពាក្យទន់ ស្រដីឲ្យអន់ ស្រាយទោសនោះទៅ។
ទោះបីបើប្តីប្រដៅ ចូរនាងចាំនៅ ទុកក្នុងអាត្មា។
ពាក្យពេចន៍កុំភ្លេចឡើយណា ក្រែងឆ្លងម្តេងម្តា ត្បិតបានផ្តាំស្រាប់។
ព្រោះឯងមិនក្រែងមិនស្តាប់ ពាក្យគេបង្គាប់ បង្អើតតែឈ្លោះ។
ឥតសុខអាក្រក់តែឈ្មោះ ឮគេប្រឈ្លោះ មិនចេះហៅល្ហៃ។
នេះពុំរាប់ជាស្ត្រីទេ ជាអ្នកប៉ោឡៃ ចិត្តចោរឯកទង។
ឲ្យមាត់បង្គ្របប្តីផង ឲ្យគេស្តាប់ហោង ថាឯងគ្រាន់បើ។
គឺមោះនាងនោះមិនប្រើ មិនបើកឲ្យដើរ បញ្ជើឲ្យទេ។
ទោះបីប្តីប្រើមាសមេ កុំកូនចំអែរ[៨] ចំអៀកមិនទៅ។
ឆ្ងាយជិតកុំគិតរង់នៅ ក្រោកក្រេសដើរទៅ កុំឲ្យប្តីជេរ។
កុំទៅនៅយូរផ្ទះគេ រវល់ទំនេរ រវៀសមកណា។
ហៃកូនខ្លីមខ្លួនមាតា ជាស្រីនេះណា កម្រណាស់នាង។
មិនថាត្បិតល្អរូបរាង មិនរើសត្បិតជាង ចេះការទាំងគ្រប់។
មិនបានស្គាល់ទិគោរព ស្គាល់ទេឧបទ្រព ទាំងឯប់ប្រការ។
ហៅតែនឹងល្អរូបា ពិតហើយចេះការ គួរកោតដោយយ៉ាង។
មួយរូបល្អសសន្លាង[៩] ឥតគេធ្មឹមខាង ច្បាប់ផងមិនចេះ។

ល្អពិតគំនិតមិនផេះ ទោះខ្មៅក្រដេះ ការសោតសមគួរ។
គឺមោះនាងនោះមិនជួ ចេះដឹងសមគួរ ស្គាល់អស់ឥរិយា។
នេះឯងពីព្រេងលោកថា ហៅល្អរូបា កបកល្យាណី។
បៃហកូនស្រីស្ងួនពិសី ម្ដាយប្រាប់អំពី ឧបទ្រពចង្រៃ។
កាន់ក្បាលប្ដីហើយរកចៃ មិនបានលើកដៃ បិទទូលសំពះ។
លោកទុកស្មើកុកទំផ្ទះ រង្គំរង្គះ នឹងបង់អស់ទ្រព្យ។
កន្លងជើងប្ដីពុំគាប់ ព្រោះចិត្តចង់ឆាប់ រំលងជើងប្ដី។
ស្មើសត្វលលកស៊ីខ្មោចខ្ចី ហើយប្រចាលអប្រិយ កើតព្យាធិរោគា។
ចង្រៃមួយនៃរាល់គ្នា ចេញចូលមាត់ទ្វារ ពុំបានបិទបាំង។
ធ្វេសប្រាណខុសខានមិនរាំង មិនរុញបំបាំង មើលយល់សាយសុស។
ទុកស្មើគេអុជចន្លុះ ឲ្យចោរចូលផ្ទះ យកទ្រព្យទាំងឡាយ។
ស្រីមួយសើចលេងក្អាកក្អាយ ឮលេខចម្ងាយ រំលងផ្ទះបី។
ស្មើសត្វចចាត[៦]បក្សី ចូលភូមិផងក្ដី ចង្រៃក្ដាត់ណា។
ស្រីមួយដេកដាក់កាយា ប្រះប្រែអាត្មា ឲ្យខ្នងទៅប្ដី។
ទុកស្មើពស់ក្រាយ[៧]អប្រិយ ឡើងផ្ទះឥតបី ឥតបើគណនា។
ចង្រៃកាចក្រៃពុំជា នឹងព្រាត់ប្រាសគ្នា ពុំបានវែងឆ្ងាយ។
ស្រីមួយសក់វែងអន្លាយ រំសុសរំសាយ សក់សោតរេរា។
នៅមាត់អណ្ដូងមាត់ទ្វារ បីដូចមជ្ឈរា ឆ្នាលាក់ក្រចក។
ចង្រៃឥតបីបើរក រេរាសំកក មិនចុកសក់ងាយ។
ស្រីមួយដើរទៅទាត់ជាយ ឮលាន់ស្មើរធ្លាយ ប្រថពីសន្ធឹក។
សំពត់ដាច់ដាចមិននឹក ដើរឮគគឹក ស្មើស្គររន្ទះ។
ញាំញើសំណើរលេះ ដាក់ជើងលើផ្ទះ គគ្រាំងគគ្រេង។
កក្រើកផ្ទះទាំងបីល្វែង ដូចកលគេសែង របស់ចេញទៅ។
ស្រីមួយឃើញទ្រព្យនៅផ្លូវ កន្លងហួសទៅ មិនចាប់ចេញទុក។

ពុំចេះចំណេះទៅមុខ ពុំចេះដាក់ទុក វាយរាល់តែល្វែង។
ទ្រព្យនោះរលោះចេញឯង ចង្រៃទាស់ទែង ធ្វើឲ្យអន្តរាយ។
ទោះធីចំណីនូវបាយ លបលួកកកាយ ពមេ[៨]ពុំសណ្តាប់។
កូនអើយនេះហើយចូរស្តាប់ ហៅក្តីឧបទ្រព ទាំងផងប្រការ។
ឲ្យចៀសអស់ទាំងនេះណា ឲ្យរៀនលក្ខណា ទាំងប្រាំពីរផង។
គឺព្រះមានបុណ្យកន្លង ទេសនាចែងចង ជាបទគាថា។
មួយមាតុមួយមិត្តភរិយា កាតុភរិយាជាតិ ទាសភរិយាផង។
ទាំងបួនប្រសើរឥតហ្មង គួរឲ្យចាំចង ទុកក្នុងអង្គា។
រីឯហៅមាតុភរិយា ប្រពន្ធនោះជា លោកទុកស្មើម្តាយ។
ចរិតបីប្រការក្នុងកាយ មួយចង់ខ្វល់ខ្វាយ ប្រយោជន៍ឲ្យប្តី។
បានច្រើនរុងរឿងព្រល្បី មិនឲ្យអាប់ប្តី ឲ្យបានសក្តិយស។
មួយបើប្តីស្លៀកពាក់ចាស់ យកថ្មីឲ្យផ្លាស់ ចាស់ស្លៀកខ្លួនឯង។
ចេះរៀបរណ្តាប់តាក់តែង ចំណីផងស្ងែង រកមកឲ្យប្តី។
មួយបើប្តីឈឺថ្កាត់អ្វី ព្រួយប្រឹងមើលប្តី រកថ្នាំសង្កូវ។
រកពេទ្យមេមត់នូវគ្រូ គ្រោះយាមគន់គូរ មើលប្តីឲ្យជា។
រីឯហៅកាតុភរិយា ប្រសើរសោភា ប្រពន្ធស្មើបង។
នោះមានចរិតពីរផង ដូចប្អូននិងបង ចិត្តមូលមួយប្រាណ។
មួយធ្វើឲ្យប្តីក្សេមក្សាន្ត របស់ប្តីបាន ចេះទុករក្សា។
មួយទោះព្រពាក្យអ្នកណា គេតិះដៀលថា ស្រដីពីប្តី។
ពុំត្រូវអាស្រូវអប្រិយ ចេះការកើតក្តី បែរបានជាសុខ។
ទោះបីបើប្តីមានទុក្ខ គិតឲ្យបានសុខ យកខ្លួនធានា។
មួយសោតឯមិត្តភរិយា មានចរិតជា បីប្រការមិញ។
បីដូចកលមិត្តសម្លាញ់ មានចិត្តអស់អញ មិនឲ្យមានហ្មង។
បីដូចកលប្អូននិងបង ប្រាសយូរលង់ហោង ទើបមកជួបគ្នា។

មានចិត្តប្រតិព័ទ្ធមហិមា ត្បិតបានជួបគ្នា មិនឲ្យមានហ្មង។
មួយមានមារយាទកន្លង ទោះឃើញប្រុសផង មិនល្មៀងចិត្តទៅ។
រីទាសភរិយានោះកូវ ក្នុងមាត្រាត្រូវ ប្រពន្ធខ្ញុំប្ដី។
ចរិតប្រាំបីប្រការខ្ទី មួយចិត្តខ្លាចប្ដី ក្រែងប្ដីវាយជេរ។
ប្រុងចិត្តការគិតខ្វាសគេ មិនឲ្យប្ដីជេរ បន្ទោសខ្លួនបាន។
ទោះខឹងប្ដីក្រៃប៉ុន្មាន មិនចេះហៅហាន ឆ្លើយឈ្លោះតមាត់។
មួយទោះប្ដីនោះកាចក្អត់ ខឹងដល់វាយវាត់ ជេរចោរឯកទង។
មិនហ៊ានឆ្លើយឈ្លោះរំលង តតបទៅផង ក្រែងពុកេរ្តិ៍ឆ្ងាយ។
មួយចេះប្រដាប់រៀបបាយ ប្ដីដើរជិតឆ្ងាយ មិនហ៊ានបរិភោគ។
អត់ចាំទម្រាំប្ដីមក ជួបជុំទើបយក បរិភោគផងគ្នា។
នេះឯងហៅទាសភរិយា សម្ដេចភគវា ទេសនាប្រោសប្រាប់។
បើអស់ស្រីណាបានស្ដាប់ យកទុកជាច្បាប់ ក្នុងប្រាណសព្វថ្ងៃ។
លុះអស់អាយុក្សិណក្ស័យ បានទៅកើតព្ឋ តុសិតសួគ៌នាយ។
នឹងបានក្សេមក្សាន្តពណ្ណរាយ សេពសុខសប្បាយ និរទុក្ខកយា។
រីឯប្រពន្ធពុំជា ពេជ្ឈឃាតភរិយា ចរិតមានបួន។
កុំឲ្យយកទុក្ខក្នុងខ្លួន ឲ្យចៀសចេញជួន កើតកម្មវេរា។
មួយចិត្តគំនិតចង់ជា ឆ្លាស់ឆ្លើយបំពារ បំពានឲ្យប្ដី។
ប្រទូសរឹងរូសខ្ទូវខ្ទី មិនចេះចាញ់ប្ដី ថាឯងគ្រាន់បើ។
ឆ្លើយឆ្លងសូរសងបណ្ដើរ ចង់ឈ្លោះឲ្យស្មើ ឲ្យលើសប្ដីវិញ។
មួយមិនចង់ធ្វើបំពេញ បង្អាប់ប្ដីវិញ ឲ្យថ្កើងខ្លួនឯង។
អាងចេះជៀលតិះពុំក្រែង ឲ្យប្ដីស្ដាប់ឯង ដោយចិត្តអន្ធពាល។
មួយមានចិត្តនោះស្រីបស្រាល ចង់ត្រេកត្រអាល ចោលពេញមុខប្ដី។
មួយចិត្តទ្រឹស្តិទ្រុស្តអប្រិយ ចង់សម្លាប់ប្ដី ស្រឡាញ់ប្រុសទៀត។
គិតកាប់សម្លាប់បង់ម្សៀត នឹងយកប្រុសទៀត ធ្វើប្ដីមរណា។

រីឯសត្រូវភរិយា ចរិតពុំជា ប្រាំពីរប្រការ។
មួយមិនខ្លាចប្តីអាត្មា បង្គាប់ត្រង់ណា ពុំធ្វើតាមចិត្ត។
មួយទ្រើងទ្រមឹងស្ងៀមស្ងាត់ ប្តីសួរបីម៉ាត់ ពុំស្រដីផង។
មួយប្តីស្រដីគន្លង ប្រដៅច្បាប់ផង ពុំចូលចិត្តស្តាប់។
មួយមិនចង់ឲ្យប្តីគាប់ មិនចង់ប្រដាប់ ឲ្យប្តីថ្កុំថ្កើង។
មួយទោះនឹងស្រដីឡើង ពាក្យធំចចើង ចចេសនឹងប្តី។
មួយទោះប្តីលោះខ្ញុំស្រី វាបម្រើប្តី មិនឲ្យអាក់អន់។
ឃើញគាប់រឹងស្អប់ក្តាញ់ក្តាន់ ក្នុងចិត្តប្រច័ណ្ឌ ជេរថានាយអាយ។
មួយត្បិតប្តីមានសាហាយ ហួរហែកសុសសាយ ឲ្យប្តីអាស្រូវ។
រីចោរភរិយានោះកូវ ចរិតពុំត្រូវ មានបីប្រការ។
មួយចង់ចាយទ្រព្យប្តីណា ឲ្យខូចអសារ មិនគង់ជាល្អ។
មួយប្តីឃ្លាតខ្វីខំរក៏ របស់បានមក៏ មិនថែទាំទុក។
លួចឲ្យទៅម្តាយឪពុក ប្តីសួររកមុខ មិនប្រាប់ឡើយណា។
មួយខ្ជិលមិនចង់ធ្វើការ កុហកមុសា ថាឯងរវល់។
ដេកលេងចំខែងអស់កល លុះប្តីគេយល់ ពុតធ្វើជាឈឺ។
ទទូរដេកថ្ងូរហ៊ឹៗ ប្តីហៅមិនឮ ពុតចង់តែស្លាប់។
នេះហៅប្រពន្ធពុំគាប់ ស្រីណាកាន់ខ្ជាប់ ពុំដែលរសាយ។
លុះអស់អាយុក្ស័យក្លាយ ធ្លាក់ទៅអបាយ ទាំងបួនចំពូក។
តែងនឹងរងទុក្ខរងសោក រំដោះរួចមក កើតជាមនុស្សខ្វើយ។
ហេតុអកុសលនេះហើយ ត្បិតខ្លួនឥតត្រើយ ធ្វើខុសគន្លង។
ខុសវត្តប្រតិបត្តិឆ្គាំឆ្គង មិនរៀងមិនរង ខុសនឹងច្បាប់ស្រី។
មាក់ងាយនោះមានប្រាំបី មានក្នុងបាលី ព្រះធម៌លោកថា។
មាក់ងាយមួយនោះឯងណា ត្បិតប្តីពិការ មិនបានមាំមួន។
ខឹងស្អប់ធុញថប់មិនទ្រាំ មិនមានរកថ្នាំ គ្រូគ្រោះមេមត់។

មើលប្ដីឲ្យជាឆាប់ផុត ខឹងវិញមិនអត់ បន់ឲ្យប្ដីស្លាប់។
មាក់ងាយមួយប្ដីខ្សត់ទ្រព្យ គ្មានកេរកោះគាប់ ស្មើនឹងអាត្មា។
ដៀលត្មះថាច្រាសដោយសារ ព្រោះខ្ជិលធ្វើការ ទើបគ្មានរបស់។
មាក់ងាយត្បិតប្ដីអប្បយស ឯងត្រកូលខ្ពស់ ពូជពង្សពុំស្មើ។
ឆ្មើងខ្លួនឲ្យប្ដីបម្រើ ឈ្លោះឡើងហើយដើរ ដៀលត្មះពូជពង្ស។
មាក់ងាយមួយត្បិតប្ដីល្ងង់ ខ្លៅខ្លួនទ្រមង់ ទ្រមក់ឃឹតឃូរ។
ដៀលត្មះពុំចេះអាសូរ សម្ដីខ្មោះខ្មូរ មិនក្រែងប៉ុនសក់។
មាក់ងាយមួយប្ដីអាក្រក់ សាច់ខ្មៅប៉ប៉ក់ មុខអុតសុីសុស។
កន្ទ្រល រោងរលក្រអុះ សក់ស្កាញស្កូវសុស ពោះធំប៉ុនពាង។
ខ្លួនឯងចិញ្ចែងរូបរាង ខ្លួនសល្អជាង ថាប្ដីមិនសម។
មាក់ងាយមួយប្ដីមិនខំ ធ្វើការលេលំ ឡែឡូដើរលេង។
ឆ្លៀតឆ្លើយបោះពាក្យគគ្រេង ឈ្លោះជេរមិនឈ្វេង គិតខុសមាត្រា។
មាក់ងាយមួយប្ដីផឹកស្រា ស្រវឹងចោលការ ដើរលេងតែតោ។
ពាក្យភ្លេងវាំច្រៀងឡេវៗ ឲ្យឆ្អែព្រុសឆោ ផ្អើលភ្ញាក់កូនចៅ។
ឮមាត់ប្ដីហើយខឹងក្ដៅ ប្រទេចជេរទៅ តាមដោយចិត្តក្ដាញ់។
មាក់ងាយមួយទៀតនោះមិញ ត្បិតប្ដីស្រឡាញ់ លលូកប្រឡែង។
មួលបិចចាក់ចុចជាល្បែង មិនមានកោតក្រែង បានចិត្តជេរវិញ។
ត្បិតតែយល់គេស្រឡាញ់ ស្រដីផងមិញ គំរោះគំរើយ។
ធ្វើក្ដាញ់បែរចេញព្រងើយ គេនឹងកន្តើយ ក្ដិចក្ដក់មាយា។
ពុំបានក្សេមក្សាន្តនឹងគ្នា មាក់ងាយនេះជា គំរប់ប្រាំពីរ។
កូនអើយនេះហើយច្បាប់ស្រី ឲ្យកូនពិសី រករៀនរក្សា។
យកទុកក្នុងអង្គអាត្មា ប្រសើរក្ដាត់ណា កើតសុខសួស្ដី។
ប្រសើរទាំងនាលោកិយ ទោះបរលោកក្ដី សឹងលុះប្រាថ្នា។
ទោះចិត្តគន់គិតសច្ឆា ជាពុទ្ធមាតា សឹងបានបរិបូរណ៍។

ដូចចិត្តឆុតឆាប់ពុំយូរ     កបកើតសម្បូរ     សម្បត្តិទ្រព្យផង។
កើតយសខ្ពង់ខ្ពស់កន្លង     យឺនយូរឥតហ្មង     ដូចក្តីប្រាថ្នា។
ច្បាប់នេះឧត្តមថ្លៃថ្លា     ទោះស្រីឯណា     ឮហើយមានភ័ព្វ។
ជាល្អកម្របានស្តាប់     ស្តាប់ហើយចូរចាប់     ចូរចាំគ្រប់គ្នា។
បានដល់មគ្គផលសួគ៌ា     ប្រសើរសោភា     ចូរចាំកុំភ្លេច។
ចរចាអស់អាថ៌ពាក្យពេចន៍     ពាក្យពិតកាព្យកិច្ច     បរិបូរណ៍ប្រពៃ។
ប្រាជ្ញាប្រែប្រិវឹងនាមនៃ     ខ្ញុំឈ្មោះ**ម៉ឺន មៃ**     មែនមានសទ្ធា។
មានចិត្តក្បួចគិតកាព្យា     កបកើតជ្រះថ្លា     ត្រេកត្រង់កុសល។
សច្ឆាប្រាថ្នាមគ្គផល     ផុរផុសយោបល់     លេចលើកទុកនៅ។
ទោះបីសេចក្តីខុសត្រូវ     សូមទានតម្រូវ     តម្រង់ឲ្យផង។
កុំត្អូះតិះដៀលឡើយហោង     សូមសាងផលផង     ទុកតសាសនា។
សម្រាប់ជាច្បាប់មាត្រា     សូរេចបការា     បរិបូរណ៍ចែងចប់៕

# ពន្យល់ពាក្យ

1. ↥ គម្ដែង គំម្ដែង ដើង ដ ឬ គំ-ម៉ះ ដែង ( ន. ) (ក្លាយឃ្លាតមកពីពាក្យខ្មែរ ក្នុងសម័យបុរាណព្រេងនាយថា ក្រម្រតាង > ក្រម្រតេង > ក្រម្រតែង) មានន័យថា ព្រះតេជព្រះគុណ; លោកជាម្ចាស់ ។ លុះចំណេរកាលតៗមក ខ្មែរយើងប្រើពាក្យនេះ សំដៅសេចក្ដីថា លោកអ្នកមានបុណ្យច្រើនគួរជាទីគោរព គួរធ្វើសក្ការបូជា; លោកអ្នកមានស័ក្តិយសខ្ពង់ខ្ពស់ ។ គម្ដែងក្រឡាស្វាមី, ប្ដី ។ គម្ដែងផ្ទៃក្រោម ព្រះរាជា, ក្សត្រិយ៍ទ្រង់រាជ្យ (មើលក្នុងពាក្យ ផ្ទៃ ទៀតផង) ។ គម្ដែងសង្ឃ ព្រះភិក្ខុសង្ឃជាទីគោរព : បពិត្រព្រះគម្ដែងសង្ឃ.... ។
2. ↥ ព្រៃ ( ន. ) សំពត់សូត្រដោយបែប : ព្រៃលាត, ព្រៃផ្កា ។ សំពត់អំបោះដោយបែបក៏ហៅព្រៃ ខ្លះដែរ ព្រៃអំបោះ ។
3. ↥ ក្រញឹង ( កិ. វិ. ) ពាក្យសម្រាប់ចម្រើនពាក្យខឹងឲ្យឃើញប្លែកឡើង : ខឹងក្រញឹង ។
4. ↥ ចំអែ ( កិ. ) បំពើងទ្រូងទៅមុខ : អង្គុយចំអែ, ឈរចំអែ ។ ចំអៀកចំអែ ចំអែដោយចំអៀក ។
5. ↥ សន្លាង សន់-ល៉ាង ( គុ. ) សជ្រះស្អាត: សសន្លាង ។ ថ្មីទែង, ថ្មីស្អាត : ថ្មីសន្លាង ។ ដែលល្អសមរម្យមិនឆ្គង : ល្អសន្លាង, រូបល្អសន្លាង ។
6. ↥ ចចាត ( ន. ) សត្វបក្សីមួយប្រភេទ សម្បុរខៀវខាងខ្នង ខាងក្បាល ឯខាងពោះក្រហម ក្បាលធំចំពុះក្រហម បរិភោគត្រីជាអាហារ ជាសត្វដេញឆ្នាក់ : ចចាតឆ្នាក់, ទាក់ចចាត, ហ្មចចាត ។
7. ↥ ក្រាយ ( ន. ) ឈ្មោះពស់មួយប្រភេទមានពិសខ្លាំងមានទ្រនុងខ្នងជាអាវុធ អាចប្រាសឲ្យមុតបាន : ពស់ក្រាយ ។
8. ↥ ពម ( កិ. ) ចាប់អាហារដោយដៃដាក់ក្នុងមាត់ខ្លួនឯង : ពមបាយ ។ ពមញ៉ាត់ៗ (ពមញ៉ាត់-ពមញ៉ាត់) ពមដោយចាប់ញ៉ាត់ៗប្រញាប់ប្រញាល់ឲ្យបានឆាប់ឆ្អែត : ស៊ីឆាប់ឡើងពមញ៉ាត់ៗទៅ ! (ព. សា., ព. ស្ន.) ។